云南日报
YUNNAN DAILY PRESS GROUP
云南日报报业集团
No.125

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

YUNNAN DAILY
PRESS GROUP
english.yunnan.cn

ឆ្នាំទី 25 លេខ 7435 ថ្ងៃសុក្រ ទី 15 ខែ កញ្ញា ឆ្នាំ 2017

## ស្វែងរកការចងចាំអំពីប្រាសាទអង្គរវត្ត

***ដោយៈម៉ៅ ភឹងហ្វី (ទីភ្នាក់ងារព័ត៌មាន ស៊ីនហួចិន)***

មុនពេលទៅសម្តែងកម្មវិធីសិល្បៈ"ស្នាមញញឹមអង្គរ"ម្តងៗ អ្នករាំរបាំខ្មែរឈ្មោះ ភិក ទិក តែងតែត្រូវទៅអុជធូបនិងបន់ស្រន់ ។ រាល់ពេលឡើងឆាកសម្តែង គាត់ត្រូវដើរតួជាអប្សរា ដើម្បីបង្ហាញពីប្រវត្តិអង្គរជូនចំពោះទស្សនិកជនដែលមកពីគ្រប់ ទិសទីលើពិភពលោក ។ គាត់បានបញ្ជាក់ដោយមានភាពសប្បាយរីករាយ ថា ខ្ញុំសប្បាយណាស់ដែលអាចចូលរួមផ្សព្វផ្សាយអំពីវប្បធម៌អង្គរតាមរយៈការសម្តែងកម្មវិធីសិល្បៈ"ស្នាមញញឹមអង្គរ"។



ឈុតឆាកនៃការសម្តែងរបាំរបស់ក្រុមសិល្បករស្នាមញញឹមអង្គរ (រូបថតដោយ Wang Bangxu )

កម្មវិធីសម្តែងសិល្បៈ"ស្នាមញញឹមអង្គរ" ដែលរួមគ្នាបង្កើតដោយក្រុមហ៊ុនវិនិយោគមុខរបរវប្បធម៌ខេត្តយូនណានគ្រុប និងស្ថាប័នវប្បធម៌កម្ពុជានោះ បានទទួលការចូលរួមពី សិល្បករសិល្បការិនីចិននិងកម្ពុជា ។ ក្នុងអំឡុងពេលពីខែវិច្ឆិកាឆ្នាំ ២០១០ ដល់ចុងខែសីហា ឆ្នាំ ២០១៧ កម្មវិធីសម្តែងសិល្បៈនេះបានត្រូវសម្តែងជាង៣០០លើកនិងបានទាក់ទាញទេស ចរជាតិនិងអន្តរជាតិប្រហែល ១,៥លាននាក់ ។

លោក ហ្វូ ខាយធីង អគ្គនាយកនៃក្រុមហ៊ុនវិនិយោគសិល្បៈខេត្តសៀមរាបប្រទេសកម្ពុជា បានប្រាប់អ្នកកាសែតថា ក្នុងកម្មវិធីសម្តែងសិល្បៈ"ស្នាមញញឹមអង្គរ"នេះ អ្នកទទួលខុសត្រូវចំពោះការដឹកនាំរឿងការរៀបចំភ្លេងនិងរបាំជាដើមសុទ្ធតែជាសិល្បករសិល្បការិនីចិន ។ ប៉ុន្តែដើម្បីបង្ហាញយ៉ាងពិតប្រាកដអំពីរចនាបថវប្បធម៌អង្គរអ្នករាំរបាំភាគច្រើនជាជនជាតិខ្មែរ។

លោកបន្តទៀតថា ក្នុងគោលបំណងនៃការបង្ហាញពីវប្បធម៌ដ៏ត្រចះត្រចង់របស់រាជវង្សអង្គរ សិល្បករសិល្បការិនីចិនបានទៅសិក្សានៅតំបន់អង្គរជាច្រើនលើកច្រើនសា ដើម្បីប្រមូលនូវព័ត៌មានពាក់ព័ន្ធ ហើយបានរក្សាទំនាក់ទំនងជិតស្និទ្ធ និងបង្កើតកិច្ចសហប្រតិបត្តិការស្អិតល្មួតជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈកម្ពុជា ដើម្បីរៀបចំការសម្តែងកម្មវិធីសិល្បៈ"ស្នាមញញឹមអង្គរ"នេះឱ្យកាន់តែមានភាពល្អប្រសើរ ។ ភាគីទាំងពីរបានរួមគ្នាបង្កើតស្នាដៃសិល្បៈដ៏ល្អឥតខ្ចោះមួយនេះ តាមរយៈការធ្វើកិច្ចសហប្រតិបត្តិ-ការដោយមានភាពស្មោះត្រង់ និងបានបង្ហាញជូនពិភពលោកទាំងមូលនូវស្នាដៃវប្បធម៌ខ្មែរដ៏ល្អប្រណីតដោយផ្អែកលើគំនិតច្នៃប្រឌិតរបស់ប្រទេសចិន។

លោក សូម៉ាណាត ទស្សនិកជនខ្មែរមួយរូប ដែលមានអាយុ ៣៥ ឆ្នាំហើយ ។ បន្ទាប់ពីទស្សនាកម្មវិធីសម្តែងសិល្បៈ"ស្នាមញញឹមអង្គរ" លោកបានសម្តែងនូវមោទនភាពផ្ទាល់ខ្លួនភ្លាមៗថា ខ្ញុំឃើញជនបរទេសច្រើនមកទស្សនាកម្មវិធីសម្តែងសិល្បៈនេះ ។ ខ្ញុំជឿជាក់ថា ពួកគេនឹងអាចមានការយល់ដឹងកាន់តែច្រើនអំពីប្រវត្តិសាស្ត្រ និងវប្បធម៌នៃរាជវង្សអង្គរតាមរយៈកម្មវិធីសម្តែងសិល្បៈនេះ ។

លោកបានគូសបញ្ជាក់ថា "ស្នាមញញឹមអង្គរ"មិនគ្រាន់តែបានជំរុញការផ្លាស់ប្តូរវប្បធម៌រវាងប្រជាជននៃប្រទេសទាំងពីរចិន និងកម្ពុជា ប៉ុណ្ណោះទេ ថែមទាំងបានធ្វើឱ្យទេសចរនៃបណ្តាប្រទេសនានាមានការយល់ដឹងកាន់តែច្រើនអំពីវប្បធម៌ខ្មែរទៀតផង ។ វាបានបង្ហាញដោយគ្រប់ជ្រុងជ្រោយអំពីទស្សនៈ"ចែករំលែកគ្នាតភ្ជាប់គ្នា និងច្របាច់បញ្ចូលគ្នា"ក្នុងដំណើរនៃការស្ថាបនា"ខ្សែក្រវាត់មួយ និងផ្លូវមួយ" ៕

## ក្រុងលីជាំង និងស្រុកឈឹងជាំង បង្ហាញខ្លួនក្នុងទិវាភាពយន្ត Venice

កាលពីថ្ងៃទី៣០ ខែសីហា ដល់ថ្ងៃទី៩ ខែកញ្ញា ទិវាភាពយន្ត Venice លើកទី៧៤បានរៀបចំនៅ ប្រទេសអ៊ីតាលី ។ តាមប្រភពព័ត៌មានបានឱ្យដឹងថា ក្រុងលីជាំង និងស្រុកឈឹងជាំងនៃខេត្តយូនណានប្រទេសចិនបានរៀបចំសកម្មភាព "ផ្តោតអារម្មណ៍ទៅលើប្រទេសចិនពិព័រណ៍ទីតាំងថតភាពយន្តស្អាតជាងគេក្នុងប្រទេសចិន" ដើម្បីដាក់តាំងបង្ហាញជូនពិភពលោកនូវទេសភាពស្រស់ស្អាតព្រមទាំងធនធានវប្បធម៌ និងទេសរណ៍ដ៏ពិសេសនិងទាក់ទាញរបស់ប្រទេសចិន ។

ក្រុងលីជាំងស្ថិតនៅស្របគ្នានៃខេត្តយូនណាន ស៊ីឈួន និងទីបេត៍ ដែលបានត្រូវគេសន្មតជាទីក្រុងមួយក្នុងចំណោម "កូនក្រុងទាំង១០០ ដែលគួរជាទីដើរលេងម្តងលើភពផែនដី" ហើយបានទទួលងារជាក្រុងដែលមានបរិស្ថានល្អសម្រាប់ការរស់នៅមនុស្សជាតិនិងជាក្រុងទេសចរណ៍ល្អឆើតឆាយក្នុងប្រទេសចិន ។ ក្រុងបុរាណលីជាំង សាលារដ្ឋបាលត្រកូលមូ ឃុំបុរាណ-ស៊ូហឺ ភ្នំព្រឹលយូឡុង និងសួនរុក្ខគុក្កសាស្ត្រជាតិភ្នំឡាវជូនជាដើម បានក្លាយជាតំបន់ទេសចរណ៍អន្តរជាតិល្បីឈ្មោះលើពិភពលោក ។

ស្រុកឈឹងជាំងស្ថិតនៅភាគអាគ្នេយ៍នៃក្រុងគុនមីង ដែលមានអាកាសធាតុល្អប្រសើរ និងទេសភាពស្រស់ស្អាត ។ នៅឆ្នាំ២០១៦ ស្រុកឈឹងជាំងបានត្រូវអាជ្ញាធរទេសចរណ៍ជាតិចិនដាក់បញ្ចូលក្នុង "បញ្ជីឈ្មោះតំបន់ទេសចរណ៍គំរូគ្រប់ជ្រុងជ្រោយថ្នាក់ជាតិ" ក្រុមទី២ របស់ប្រទេសចិន ។ ក្នុងឱកាសទិវាភាពយន្តនេះ ស្រុកឈឹងជាំងបានផ្សព្វផ្សាយអំពីតំបន់ទេសចរណ៍មួយចំនួនដូចជា បឹងហ្វូស្សៀន ភ្នំម៉ាវផាន និងទីសំណល់វប្បធម៌យូនណានបុរាណជាដើម ៕



ទិដ្ឋភាពទីក្រុងបុរាណលីជាំងនៅជើងភ្នំ ព្រិលនាគ (រូបថតដោយស៊ីហ្សួរ)

## ពិធីចុះហត្ថលេខាលើគម្រោងសាងសង់តំបន់មុខរបរអាស៊ាននៅខេត្តយូនណានប្រារព្ធនៅក្រុងគុនមីង





ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងឧស្សាហកម្មរវាងយូនណាន និងអាស៊ាន (រូបថតដោយ Yu Jinmeng )

នៅថ្ងៃទី២៩ ខែសីហា ពិធីចុះហត្ថលេខាលើគម្រោងសាងសង់តំបន់មុខរបរអាស៊ាននៅខេត្តយូនណានបានប្រារព្ធនៅក្រុងគុនមីងនៃខេត្តយូនណាន ។ សាលាក្រុងគុនមីង សាលារដ្ឋបាលតំបន់ភូមិភាគកណ្តាលថ្មីនៃខេត្តយូនណាន និងក្រុមហ៊ុនហានតឺប្រទេសសិង្ហបុរីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រ ។

ខេត្តយូនណានជាទីប្រសព្វនៃរបៀងសេដ្ឋកិច្ចបង់ក្លាដែស-ចិន-ឥណ្ឌា-មីយ៉ាន់ម៉ា និងរបៀងសេដ្ឋកិច្ចចិន-ឧបទ្វីបឥណ្ឌូចិន ។ បទពិសោធន៍ដ៏ជោគជ័យអំពីការបង្កើត និងដំណើរការតំបន់ឧស្សាហកម្មក្រុងស៊ូចូវចិន-សិង្ហបុរី និងការអភិវឌ្ឍទីក្រុងនៃប្រទេសសិង្ហបុរី នឹងត្រូវប្រើប្រាស់សម្រាប់សាងសង់ និងអភិវឌ្ឍន៍តំបន់មុខរបរអាស៊ាននៅខេត្តយូនណាននេះដើម្បីបង្កើតជាវេទិកាបើកទូលាយដ៏សំខាន់សម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការពហុវិស័យរវាងខេត្តយូនណាន និងប្រទេស អាស៊ាន និងជំរុញការធ្វើអន្តរជា តូបនីយកម្ម ហើយធ្វើឱ្យតំបន់មុខរបរអាស៊ាននេះដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៃខេត្តយូនណាន និងក្លាយទៅជាតំបន់មុខរបរច្នៃប្រឌិតអន្តរជាតិថ្មីដែលមានឥទ្ធិពលខ្លាំង លើវិស័យសេដ្ឋកិច្ចក្នុងតំបន់ ៕ **ដោយ យូ ជីនម៉ឹង**

## ក្រុមសុខាភិបាលចិនចេញដំណើរទៅកាន់ប្រទេសអ៊ូហ្គង់ដាជាលើកទី១៨

ពេលថ្មីៗនេះ ក្រុមសុខាភិបាលចិនបានរៀបចំពិធីចេញដំណើរទៅកាន់ប្រទេសអ៊ូហ្គង់ដាជាលើកទី១៨ នៅមន្ទីរពេទ្យលេខ១ នៃសាកលវិទ្យាល័យវេជ្ជសាស្ត្រក្រុងគុនមីង ។

តាមការឧទ្ទេសនាមបានឱ្យដឹងថា គ្រូពេទ្យជំនាញដែលមកពីផ្នែកផ្សេងៗ រួមមានផ្នែកចាក់ថ្នាំស្ពឹក ផ្នែកព្យាបាលជំងឺត្រចៀក ច្រមុះ និងបំពង់កផ្នែកព្យាបាលជំងឺឆ្លង និងផ្នែកពេទ្យចិនសែជាដើមបានចូលរួមជាសមាជិកនៃក្រុមសុខាភិបាលនេះ។ ពេលនេះក្រុមសុខាភិបាលចិននឹងទៅជួយបណ្តុះបណ្តាលគ្រូពេទ្យនៅប្រទេសអ៊ូហ្គង់ដាហើយចែករំលែកគ្នាជាមួយពួកគេអំពីបទពិសោធន៍គ្រប់គ្រងមន្ទីរពេទ្យដើម្បីលើកកម្ពស់បច្ចេកទេស និងកម្រិតថ្នាក់សុខាភិបាលនៃប្រទេស អ៊ូហ្គង់ដា ។ ក្រៅពីនេះតាមស្ថានភាពជាក់ស្តែងនៃប្រទេសអ៊ូហ្គង់ដា និង ប្រទេសអាហ្វ្រិកផ្សេងៗទៀតក្រុមសុខាភិបាលចិននឹងខិតខំជំរុញការផ្តល់ធនធានសុខាភិបាល ដ៏ល្អប្រសើរដល់ប្រទេសអាហ្វ្រិកផ្សេងៗនាំយកថ្នាំចិនសែនិងវិជ្ជាពេទ្យចិនសែទៅប្រទេសអាហ្វ្រិក និងជំរុញការប្រើប្រាស់ថ្នាំចិនសែសម្រាប់ព្យាបាលជំងឺរបស់ប្រជាជននៅប្រទេសអាហ្វ្រិក ៕ **ដោយ ភឹន ស៊ីនឡុង**

## ជំនឿទុកចិត្តលើខ្លួន និងភាពម្ចាស់ការនៃកិច្ចសហប្រតិបត្តិការ BRICS

***ដោយៈ វ៉ាង យីវ៉ៃ (អ្នកជំនាញការនៃមហាវិទ្យាល័យសិក្សាស្រាវជ្រាវឈុងយ៉ាងនៃសាកលវិទ្យាល័យប្រជាជនចិន)***

ជំនួបរវាងអ្នកដឹកនាំនៃប្រទេស BRICS នៅក្នុងទីក្រុងស្យាមិនប្រទេសចិនបានបើកទំព័រ"ទសវត្សរ៍ពណ៌មាស"ទី ២ ដោយជោគជ័យ ហើយបានជំរុញការអនុវត្តយន្តការ"BRICS+" ការអភិវឌ្ឍវិស័យ"បណ្តាញអ៊ីនធើណេត+" និងបង្កើនការផ្លាស់ប្តូរផ្នែកវប្បធម៌រវាងបណ្តាប្រទេសនានា ។ ជាពិសេស ជំនួបលើកនេះបានធ្វើឱ្យយើងទាំងអស់គ្នាកាន់តែមានជំនឿទុកចិត្តលើកិច្ចសហ-ប្រតិបត្តិការ BRICS និងកាន់តែមានភាពម្ចាស់ការក្នុងការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការ BRICS ឱ្យកាន់តែស៊ីជម្រៅថែមទៀត ។

ជំនឿទុកចិត្តលើខ្លួនមានប្រភពពីកម្លាំងពិតប្រាកដរបស់ប្រទេស BRICS ។ អត្រាទំហំសេដ្ឋកិច្ចប្រទេស BRICS ធៀបនឹងទំហំសេដ្ឋកិច្ចទូទាំងពិភពលោកបានកើនឡើងពី១២ភាគរយដល់២៣ភាគរយ ។ ទំហំពាណិជ្ជកម្ម និងការវិនិយោគនៃប្រទេស BRICS ទាំង ៥ បានកើនឡើងយ៉ាងឆាប់រហ័សដែលបានធ្វើឱ្យប្រទេសទាំងនោះដើរតួនាទីកាន់តែសំខាន់ក្នុងអង្គការហិរញ្ញវត្ថុអន្តរជាតិសំខាន់ៗ ដូចជាធនាគារពិភពលោក និងអង្គការមូលនិធិរូបិយវត្ថុ អន្តរជាតិជាដើម ។

ជំនឿទុកចិត្តលើខ្លួនមានប្រភពពីកម្លាំងរស់រវើកនៃយន្តការសហ-ប្រតិបត្តិការ BRICS ។ កិច្ចសហប្រតិ-បត្តិការ BRICS បាននាំមកនូវកម្លាំងរស់រវើកថ្មីសម្រាប់ជំរុញការអភិវឌ្ឍពាណិជ្ជកម្ម និងការវិនិយោគអន្តរ-ជាតិ ។ ជាពិសេសកិច្ចសហប្រតិបត្តិ-ការបែបនេះមិនត្រឹមតែមានឥទ្ធិពលលើវិស័យសេដ្ឋកិច្ចនោះទេ ហើយបានបង្កើតជាក្របខ័ណ្ឌសហប្រតិបត្តិការពហុ-វិស័យ ដែលច្របាច់បញ្ចូលនូវវិស័យសេដ្ឋកិច្ច នយោបាយ និងវប្បធម៌ ។

ជំនឿទុកចិត្តលើខ្លួនមានប្រភពពីកម្លាំងទុននៃកិច្ចសហប្រតិបត្តិការ BRICS ។ បច្ចុប្បន្ន BRICS បាននិងកំពុងក្លាយជាវេទិកាសហប្រតិបត្តិការមួយដែលមានឥទ្ធិពលខ្លាំងលើពិភពលោកទាំងមូល ។ កិច្ចសហប្រតិបត្តិការមិនគ្រាន់តែមានសារសំខាន់សម្រាប់ប្រទេស BRICS ទាំង ៥ប៉ុណ្ណោះទេថែមទាំងនឹងអាចជួយជំរុញការអភិវឌ្ឍន៍ នៃប្រទេសជាទីផ្សារថ្មីនិងប្រទេសកំពុងអភិវឌ្ឍនានាក៏ដូចជាពិភពលោកទាំងមូលផងដែរ ។

ទន្ទឹមនឹងនេះ យើងត្រូវខិតខំជំរុញកិច្ចសហប្រតិបត្តិការ BRICS ដោយផ្តោតសំខាន់លើចំណុចចំនួន ៣ដូចខាងក្រោមៈ

-ជំរុញដោយមានភាពម្ចាស់ការនូវការអភិវឌ្ឍទំនាក់ទំនងអន្តរជាតិបែបថ្មី ការធ្វើសាកលភាវូបនីយកម្មបែបថ្មី និងការគ្រប់គ្រងពិភពលោកបែបថ្មី ដើម្បីបង្កើតសហគមន៍រួមវាសនាមនុស្សជាតិ ។ កិច្ចសហប្រតិបត្តិ-ការ BRICS ផ្តោតសំខាន់លើការតភ្ជាប់គ្នាផ្នែកយុទ្ធសាស្ត្រ ការកែលម្អនិងស្តារជាថ្មីឡើងវិញនូវប្រព័ន្ធបែងចែកអន្តរ-ជាតិនិងខ្សែសង្វាក់តម្លៃពិភពលោកព្រមទាំងពន្លឿនដំណើរនៃការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រង ពិភពលោកបែបថ្មីដែលរួមគ្នាពិគ្រោះពិភាក្សា ស្ថាបនា និងចែករំលែកគ្នា ។

-លើកកម្ពស់តួនាទីរបស់ប្រទេសកំពុងអភិវឌ្ឍន៍ដោយមានភាពម្ចាស់ការ ។ យន្តការ "BRICS+" ផ្តោតសំខាន់លើការសន្ទនាជាមួយប្រទេសកំពុងអភិវឌ្ឍន៍ជំរុញការធ្វើកិច្ចសហប្រតិបត្តិការរវាងប្រទេសកំពុងអភិវឌ្ឍន៍និងថែរក្សាផលប្រយោជន៍ទូទៅរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

-ជំរុញការថែរក្សាសណ្តាប់-ធ្នាប់អន្តរជាតិឱ្យកាន់តែមានយុត្តិធម៌និងភាពសមហេតុផល ។ កិច្ចសហប្រតិបត្តិការ BRICS មិនគ្រាន់តែត្រូវធ្វើជា "ម៉ាស៊ីន" សម្រាប់ពន្លឿនការធ្វើកំណែទម្រង់ប្រព័ន្ធថែរក្សាសណ្តាប់ធ្នាប់អន្តរជាតិប៉ុណ្ណោះទេ ហើយក៏ត្រូវរួមចំណែកកាន់តែច្រើនក្នុងការអភិវឌ្ឍប្រព័ន្ធពហុប៉ូលពិភពលោក និងពង្រឹងប្រជាធិបតេយ្យភាពនៃទំនាក់ទំនងអន្តរជាតិដែរ ដើម្បីផ្តល់ក្តីប្រាថ្នា និងកំណត់គម្រោងកាន់តែច្រើនសម្រាប់ជំរុញការអភិវឌ្ឍនិងស្វែងរកវិបុលភាពនៃសង្គមមនុស្សជាតិ ៕